សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ ប្រអប់សំបុត្រ ៤៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦ អ៊ីមែល: contact@licadho-cambodia.org

# នៅក្នុងទិវាអន្តរជាតិប្រឆាំងពលកម្មកុមារ អង្គការ លីកាដូ សូមឲ្យអាជ្ញាធរបញ្ឈប់ ឬសគល់នៃការប្រើពលកម្មកុមារ

អង្គការ លីកាដូ នឹងប្រារព្ធទិវាអន្តរជាតិប្រឆាំងពលកម្មកុមារ ឆ្នាំ ២០១៤ ដោយរៀបចំកម្មវិធីសហគមន៍ចំនួនពីរ កន្លែងគឺ៖ ទីមួយគឺនៅសង្កាត់ដងទង់ ខេត្តកោះកុង និងទីពីរនៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។ គោលបំណងនៃការរៀបចំព្រឹត្តិការណ៍នេះគឺដើម្បីលើកកម្ពស់ការយល់ដឹងពីពលកម្មលើកុមារនៅក្នុងវិស័យជាច្រើន និងជំរុញឲ្យសហគមន៍លើកឡើងនូវសំណួរសំខាន់ៗ ហើយនិងផ្តល់យោបល់ជូនអាជ្ញាធរមូលដ្ឋាន អំពីមធ្យោបាយបញ្ឈប់ការប្រើប្រាស់កម្លាំងពលកម្មលើកុមារ។ ទិវាអន្តរជាតិប្រឆាំងពលកម្មកុមារនឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃទី១២ ខែមិថុនា ។

ក្នុងសង្កាត់ដងទង់ ខេត្តកោះកុង អង្គការ លីកាដូ នឹងសហការជាមួយក្រុមការពារកុមារថ្នាក់មូលដ្ឋាន (CPGs) ដើម្បីរៀបចំដង្ហែរក្បួននៅថ្ងៃទី១២ ខែមិថុនា ដោយមានប្រជាពលរដ្ឋយ៉ាងតិចណាស់ ២០០នាក់ចូលរួមក្នុងការលើកកម្ពស់ការយល់ដឹងនៃការប្រើប្រាស់កម្លាំងពលកម្មលើកុមារក្នុងឧស្សាហ៍កម្មកាត់ដេរ និងនេសាទ។ នៅក្នុងព្រឹត្តិការណ៍នេះ ក្រុមការពារកុមារមានគម្រោងបង្កើតវេទិកាសាធារណៈមួយ និងធ្វើការសម្តែងល្ខោនជាមួយអ្នកទស្សនាដែលមកចូលរួមក្នុងចំណោមអ្នកចូលរួមយ៉ាងតិចណាស់ ៥០០នាក់។

ក្នុងស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ អង្គការ លីកាដូ នឹងរៀបចំកម្មវិធីសហគមន៍នៅថ្ងៃទី១៥ ខែមិថុនា ដោយមានកិច្ចសហប្រត្តិបត្តិការណ៍ជាមួយនឹងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។ ប្រជាពលរដ្ឋប្រហែលជា ៥០០នាក់ដែលមកពីបណ្តាឃុំចំនួនបីត្រូវបានគេរំពឹងទុកថានឹងមកចូលរួមក្នុងព្រឹត្តិការណ៍នេះ។ អ្នកចូលរួមនឹងដើរដង្ហែរក្បួនចម្ងាយពីមួយទៅពីរគីឡូម៉ែត្រ អមដោយរបាំប្រពៃណីជាតិ (របាំឆៃយ៉ាំ) បន្ទាប់មកអ្នកទាំងនោះនឹងចូលរួមក្នុងវេទិកាសាធារណៈ និងការសម្តែងល្ខោន។ វេទិកានេះ នឹងផ្តោតសំខាន់ទៅលើការប្រើប្រាស់កម្លាំងពលកម្មលើកុមារក្នុងរោងចក្រកាត់ដេរ និងនេសាទ។

## ប្រវត្តិពលកម្មលើកុមារ

ក្នុងឆ្នាំ២០១២ អង្គការពលកម្មអន្តរជាតិ (ILO) បានរកឃើញថាមានកុមារចំនួន ៧៥៥.២៤៥នាក់ កំពុងធ្វើការក្នុងប្រទេសកម្ពុជា។ ក្នុងនេះមានចំនួន ៤២៩.៣៨០នាក់ (៥៦.៩%) ត្រូវបានចាត់ទុកថាជាកម្មករកុមារ *ហើយមានចំនួន ២៣៦.៤៩៨នាក់ (៣១.៣%) បានធ្វើការក្នុងលក្ខខ័ណ្ឌគ្រោះថ្នាក់ដែលអ្នកទាំងនោះត្រូវបានរងផលប៉ះពាល់ពីសារធាតុ ឬសម្ភារៈគីមី។

ពលកម្មលើកុមារមានការគម្រាមកំហែងទៅដល់សិទ្ធជាមូលដ្ឋានរបស់កុមារក្នុងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ការលូតលាស់ផ្នែកបញ្ញា និងរូបរាងកាយ ការទទួលបានការការពារពីការរំលោភបំពាន និងការចូលរួមក្នុងសហគមន៍របស់អ្នកទាំងនោះ។ កម្មករជាកុមារធ្វើការទៅតាមវិស័យមួយចំនួនដូចជា៖ ការងារតាមផ្ទះ ក្នុងរោងចក្រកាត់ដេរ ការប្រមូលសម្រាម នេសាទ កសិកម្ម កម្មករឡេតដ្ឋ និងសំណង់។

ខណៈដែលទម្រង់នៃពលកម្មកុមារមួយចំនួន មានលក្ខខ័ណ្ឌគ្រោះថ្នាក់ខ្លាំង ទម្រង់ទាំងនោះតម្រូវឲ្យកុមារធ្វើការច្រើនម៉ោងដែលកុមារទាំងនោះមិនអាចចំណាយពេលទៅសាលារៀន និងទទួលបានការចិញ្ចឹមបីបាច់ និងមានទំនាក់ទំនងជាមួយមិត្តភក្តិ គ្រូបង្រៀន និងក្រុមគ្រួសារបានឡើយ។ ឧទាហរណ៍ កុមារដែលធ្វើការតាមផ្ទះមួយចំនួន ចាប់ផ្តើមធ្វើការពីពេលព្រលឹមហើយចប់ការងារនៅពេលយប់។ ដោយសារកុមារទាំងនោះធ្វើការក្នុងផ្ទះបិទជិត នេះពិតជាធ្វើឲ្យមានការលំបាកសម្រាប់អាជ្ញាធរ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីសង្កេត និងការពារសុខុមាលភាពរបស់អ្នកទាំងនោះ។

ក្នុងករណីដែលកុមារទាំងនោះធ្វើការក្នុងលក្ខខ័ណ្ឌគ្រោះថ្នាក់ អ្នកទាំងនោះមានការប្រឈមនឹងគ្រោះថ្នាក់ខ្លាំងបំផុតក្នុងការរងរបួសដែលបណ្តាលមកពីម៉ាស៊ីនដែលមានគ្រោះថ្នាក់ ឬសារធាតុគីមី។

ចំនួនដ៏ច្រើននៃកម្មករជាកុមារ ជាពិសេសអ្នកដែលធ្វើការក្នុងលក្ខខ័ណ្ឌគ្រោះថ្នាក់ គឺបានបង្ហាញយ៉ាងច្បាស់ថានេះជាការរំលោភបំពានទៅលើច្បាប់ការងាររបស់ប្រទេសកម្ពុជា ដែលបានហាមឃាត់អ្នកដែលមានអាយុតិចជាង ១៨ឆ្នាំ ក្នុងធ្វើការក្នុងលក្ខខ័ណ្ឌដែលគ្រោះថ្នាក់ (កថាខ័ណ្ឌទី២ មាត្រា ១៧៧)។ ដោយមិនមានការពង្រឹង និងការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ អាជ្ញាធរអនុញ្ញាតឲ្យក្រុមហ៊ុន និងនិយោជកកេងប្រវ័ញ្ចលើកុមារដោយមិនមានការប្រឈមមុខនឹងការផ្តន្ទាទោសតាមច្បាប់នោះឡើយ។

ទោះបីជាស្ថិតក្នុងលក្ខខ័ណ្ឌការងារគ្រោះថ្នាក់តិចជាងក៏ដោយ កម្មករជាកុមារគឺជាជនងាយរងគ្រោះផ្នែករូបរាងកាយ ផ្លូវភេទ ពាក្យសម្តី និងផ្លូវចិត្តពីសំណាក់និយោជក និងអ្នកដែលធ្វើការជាមួយ។ ប៉ុន្តែជាញឹកញាប់កម្មករកុមារមិនយល់ដឹងអំពីសិទ្ធិរបស់ខ្លួនទេ ហើយជួនកាលមានការភ័យខ្លាចថាតុលាការនឹងផ្តន្ទាទោសអ្នកទាំងនោះសម្រាប់ការធ្វើការងារខុសច្បាប់ ជាងដោះស្រាយរឿងព្រហ្មទណ្ឌ។ កុមារទាំងនោះប្រហែលជាមិនអាចឬត្រូវគេបានសម្លុតនៅពេលដែលបំពេញពាក្យបណ្តឹងប្រឆាំងនឹងអ្នកដែលធ្វើការរំលោភបំពាន ទាំងនេះហើយដែលជាមូលហេតុតម្រូវឲ្យមានអ្នកអាណាព្យាបាលស្របច្បាប់ដើម្បីការពារអ្នកទាំងនោះក្នុងតុលាការ។

ណាលី ពីឡុក នាយិកាសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានមានប្រសាសន៍ថា៖ "ពលកម្មកុមារមិនមែនត្រឹមតែជាការកេងប្រវ័ញ្ចលើកុមារប៉ុណ្ណោះទេ ប៉ុន្តែវាជារោគសញ្ញាមួយនៃបញ្ហាសង្គមដ៏ធំធេង"។ អ្នកនាងបានបន្តទៀតថា៖ "ជាពិសេស អាជ្ញាធរគឺមានសភាពយឺតយ៉ាវក្នុងការពង្រឹង និងអនុវត្តច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធនឹងការងារ។ សកម្មភាពទាំងអស់នេះត្រូវតែមានការផ្លាស់ប្តូរ"។

ម្តាយឪពុកក៏មានការទទួលខុសត្រូវចំពោះការប្រើប្រាស់ពលកម្មលើកុមារផងដែរ។ នៅតាមផ្ទះមួយចំនួនម្តាយឪពុកប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ ដែលតម្រូវឲ្យកុមារជួយទ្រទ្រង់ជីវភាពក្រុមគ្រួសារ។ ម្តាយឪពុកមិនបានពិចារណាថាតើវាខុសឬទេ ក្នុងការដែលឲ្យកុមារឈប់រៀនហើយទៅរកការងារធ្វើ។ ក្នុងករណីខ្លះទៀត ចំពោះម្តាយឪពុកមួយចំនួនច្រើនទៀត ដោយសារតែភាពក្រីក្រ គ្មានការងារធ្វើ បំណុល បញ្ហាសុខភាព និងបញ្ហាដែលមិនអាចដឹងមុនមួយចំនួនទៀត អ្នកទាំងនោះពិតជាមិនមានជម្រើសផ្សេងក្រៅពីឲ្យកូនឈប់រៀននោះទេ ហើយទៅរកការងារធ្វើដើម្បីទ្រទ្រង់ជីវភាពគ្រួសារ។

អត្រាខ្ពស់នៃការបណ្តេញប្រជាពលរដ្ឋចេញដោយបង្ខំក្នុងប្រទេសកម្ពុជា ក៏រួមចំនែកក្នុងការបង្កើតឲ្យមានពលកម្មលើកុមារផងដែរ។ ចាប់តាំងពីឆ្នាំ ២០០០មក អង្គការ លីកាដូ បានធ្វើការប៉ាន់ប្រមាណថា យ៉ាងតិចមានប្រជាពលរដ្ឋចំនួន ៥០០.០០០នាក់ ដែលស្ទើរតែស្មើនឹងពាក់កណ្តាលប្រទេសត្រូវបានរងការប៉ះពាល់ពីបញ្ហាដីធ្លីដែលពាក់ព័ន្ធជាមួយអាជ្ញាធរដ្ឋ។ កុមារមកពីក្រុមគ្រួសារដែលរងការបណ្តេញចេញបានបោះបង់ការសិក្សាដោយសារតែមិនមានមធ្យោបាយគ្រប់គ្រាន់នៅតំបន់តាំងទីលំនៅថ្មីនោះ។ កុមារផ្សេងទៀតចាប់ផ្តើមធ្វើការដើម្បីជួយម្តាយឪពុកក្នុងការស្វែងរកចរិកា បន្ទាប់ពីអ្នកទាំងនោះបានបាត់បង់នូវជីវភាពរបស់ខ្លួនកាលពីពេលមុន។

អង្គការ លីកាដូ សូមដោយទទូចដល់អាជ្ញាធរ សូមលោកមេត្តាមិនមែនត្រឹមតែផ្តោតទៅលើការលុបបំបាត់ប្រភេទនៃពលកម្មលើកុមារប៉ុណ្ណោះទេ ប៉ុន្តែក៏សូមដោះស្រាយដើមហេតុដែលបង្កឲ្យមានបញ្ហាទាំងអស់នេះផងដែរ។ អង្គការ លីកាដូ អំពាវនាវស្នើសុំឲ្យអាជ្ញាធរ៖

- បង្កើនការត្រួតពិនិត្យដើម្បីធានាថាមិនមានកុមារដែលមានអាយុក្រោម ១៨ឆ្នាំ កំពុងធ្វើការក្នុងលក្ខខ័ណ្ឌគ្រោះថ្នាក់ ឬក៏ធ្វើការច្រើនម៉ោងមិនសមស្របទៅនឹងអាយុ ដូចដែលបានគូសបង្ហាញដោយអង្គការពលកម្មអន្តរជាតិ (ILO)។ អាជ្ញាធរគួរតែដាក់ទោសលើនិយោជកដែលកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ។
- ត្រួតពិនិត្យចំពោះច្បាប់ និងបទបញ្ញត្តិមួយចំនួនដែលពាក់ព័ន្ធនឹងការងារ ដើម្បីធានាថាកម្មករកុមារទទួលបានការការពារទៅតាមច្បាប់។ អង្គការ លីកាដូ បានសង្កេតឃើញថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនទាន់បានចេញសេចក្តីប្រកាសដើម្បីធានាពីសុវត្ថិភាពរបស់កុមារដែលធ្វើការតាមផ្ទះនៅឡើយទេ។
- បញ្ឈប់ការបណ្តេញចេញខុសច្បាប់ដែលធ្វើឲ្យមានការប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ ហើយបណ្តាលឲ្យកុមារឈប់រៀនដើម្បីទៅរកការងារធ្វើ។
- ធានាថាក្រុមគ្រួសារដែលទទួលរងការបណ្តេញចេញទទួលបានសំណងត្រឹមត្រូវតាមច្បាប់ និងកន្លែងដែលតាំងទីលំនៅថ្មីដែលអាចផ្តល់លទ្ធភាពក្នុងការអាចទៅសាលារៀន និងមជ្ឈមណ្ឌលសុខភាពសម្រាប់កុមារដែលរងគ្រោះ។
- ផ្តល់អទិភាពលើយុទ្ធនាការលើកកម្ពស់ការយល់ដឹងស្តីពីពលកម្មលើកុមារនៅថ្នាក់មូលដ្ឋាន។ ខណៈពេលដែលការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមានសារៈសំខាន់ វាគឺជាតម្រូវការបន្ទាន់មួយដែលអាជ្ញាធរត្រូវអប់រំម្តាយឪពុក និងសហគមន៍នូវវិធីដែលពលកម្មលើកុមារមានការគម្រាមកំហែងលើសិទ្ធិរបស់កុមារ ហើយវាមិនមែនជាដំណោះស្រាយរយៈពេលយូរទេ សម្រាប់បញ្ហាភាពក្រីក្រ។

លោក គង់ សុជាតិ អ្នកសម្របសម្រួលផ្នែកសិទ្ធិកុមារ មានប្រសាសន៍ថា៖ "ការលុបបំបាត់ពលកម្មលើកុមារ និងដើមហេតុដែលបណ្តាលឲ្យមានបញ្ហាទាំងនេះ គឺមិនមែនគ្រាន់តែជាបញ្ហាចំពោះសិទ្ធិកុមារប៉ុណ្ណោះទេ"។ លោកបានបន្តទៀតថា "ប្រសិនបើកុមារបន្តឈប់រៀន ហើយរកការងារធ្វើ នោះការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចរយៈពេលវែងនៅកម្ពុជា នឹងជួបគ្រោះយ៉ាងខ្លាំង។ ការរំលោភបំពានពលកម្មលើកុមារ អាចនឹងបន្តរីករាលដាលឡើង ប្រសិនបើអាជ្ញាធរ និយោជក ម្តាយឪពុក និងសហគមន៍បន្តជឿថានេះមិនមែនជាបញ្ហាបន្ទាន់ ទោះបីវាជាមូលហេតុមួយក្នុងការរកប្រាក់ចំណូល ភាពក្រីក្រ និងជាទំនៀមទម្លាប់ប្រពៃណីក៏ដោយ"។

*សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖*

- ណាលី ពីឡូក នាយិកាអង្គការសិទ្ធិមនុស្ស លីកាដូ, លេខទូរស័ព្ទ៖ ០១២ ៨០៣ ៦៥០
- លោក គង់ សុជាតិ អ្នកសម្របសម្រួលផ្នែកសិទ្ធិកុមារនៃអង្គការ លីកាដូ, លេខទូរស័ព្ទ៖ ០១២ ៥៣៦ ៣០០

*អង្គការពលកម្មអន្តរជាតិ (ILO) ឲ្យនិយមន័យពលកម្មលើកុមារគឺជា៖

a) កុមារដែលមានអាយុពី ៥ឆ្នាំ ទៅ ១១ឆ្នាំ ធ្វើការងារលើសកម្មភាពសេដ្ឋកិច្ចរយៈពេលមួយម៉ោង ឬច្រើនជាងមួយសប្តាហ៍។

b) កុមារដែលមានអាយុពី ១២ឆ្នាំ ទៅ ១៤ឆ្នាំ ធ្វើការងារលើសកម្មភាពសេដ្ឋកិច្ចដែលត្រូវបានអនុញ្ញាត (មិនសូវគ្រោះថ្នាក់) រយៈពេលច្រើនជាង ១២ម៉ោងក្នុងមួយសប្តាហ៍។

c) កុមារដែលមានអាយុពី ១២ឆ្នាំ ទៅ ១៤ឆ្នាំ ធ្វើការងារដែលមានរយៈពេលតិចជាង ១២ម៉ោងក្នុងមួយសប្តាហ៍ ប៉ុន្តែធ្វើការនៅក្នុងឧស្សាហកម្ម និងកន្លែងធ្វើការដែលគ្រោះថ្នាក់។

d) កុមារដែលមានអាយុពី ១៥ឆ្នាំ ទៅ ១៧ឆ្នាំ ធ្វើការងារលើសកម្មភាពសេដ្ឋកិច្ចរយៈពេល ច្រើនជាង ៤៨ម៉ោងក្នុងមួយសប្តាហ៍។

e) កុមារដែលមានអាយុពី ១៥ឆ្នាំ ទៅ ១៧ឆ្នាំ ធ្វើការងារលើសកម្មភាពសេដ្ឋកិច្ចរយៈពេល តិចជាងឬស្មើ ៤៨ម៉ោងក្នុងមួយសប្តាហ៍ ប៉ុន្តែជាប់ពាក់ព័ន្ធទៅនឹងការងារនៅក្នុងឧស្សាហកម្ម និងកន្លែងធ្វើការដែលគ្រោះថ្នាក់។